**ប្រតិភូសហភាពអឺរ៉ុប**

**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

## សហភាពអឺរ៉ុប និងភាគីពាក់ពន្ធ ពិភាក្សាអំពីការរៀបចំផែនការយុទ្ធសាស្ត្របរិស្ថាន

***រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១២*** - ប្រតិភូសហភាពអឺរ៉ុបនៅថ្ងៃនេះ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់មួយជាមួយភាគីពាក់ព័ន្ធនៅក្នុងវិស័យបរិស្ថាននិងធនធានធម្មជាតិ ដែលជាផ្នែកមួយនៃដំណើរការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់វិស័យនេះ។

ប្រតិភូសហភាពអឺរ៉ុបបានជ្រើសរើសទីប្រឹក្សាបច្ចេកទេសចំនួនពីររូប ដើម្បីរៀបចំ និង បង្ហាញពីគំហើញដំបូងស្តីពីស្ថានភាពបរិស្ថានរបស់ប្រទេស (CEP) ដែលជាធាតុដ៏សំខាន់មួយនៃផែនការយុទ្ធសាស្ត្រសម្រាប់ប្រទេស របស់សហភាពអឺរ៉ុប (ឆ្នាំ២០១៤-២០២០)។ "សិក្ខាសាលាពិគ្រោះយោបល់ស្តីពីស្ថានភាពបរិស្ថានរបស់ប្រទេស" នៅថ្ងៃនេះ មានគោលបំណងលើកកម្ពស់និងជំរុញការចូលរួមនៅក្នុងដំណើរការនេះ ដោយបានអញ្ជើញតំណាងមកពីរាជរដ្ឋាភិបាល ម្ចាស់ជំនួយ និងដៃគូសង្គមស៊ីវិល ដើម្បីចែករំលែកទស្សនវិស័យ ផែនការ និងបទពិសោធន៍ជាមួយគ្នា។

ក្នុងការទន្ទឹងរង់ចាំទទួលការចេញផ្សាយឯកសារស្តីពីស្ថានភាពបរិស្ថានរបស់ប្រទេសនៅក្នុងខែ មេសា ឆ្នាំ ២០១២ លោកបណ្ឌិត Steffen Johnsen បានធ្វើការកត់សម្គាល់ថាៈ "*ធនធានធម្មជាតិដ៏សំខាន់របស់ព្រះរាជណាចក្រកម្ពុជា កំពុងតែមានភាពរិចរឹលក្នុងកម្រិតគួរឱ្យភ្ញាក់ផ្អើល និងបង្កការគំរាមកំហែងជាច្រើនទៀត។ ទឹក ជលផល និងព្រៃឈើ គឺជាមូលដ្ឋានគ្រឹះរបស់ប្រទេស ប៉ុន្តែទង្វើនាពេលបច្ចុប្បន្នកំពុងធ្វើឱ្យក្តីសង្ឃឹមនៃកំណើនមានភាពចុះខ្សោយ ធ្វើឱ្យអន្តរាយដល់សន្តិសុខស្បៀង និងផ្តល់ប្រយោជន៍ដល់មនុស្សតែមួយក្រុមតូចប៉ុណ្ណោះ*"។

ទីប្រឹក្សាបច្ចេកទេសអាចនឹងផ្តល់អនុសាសន៍ឱ្យសហភាពអឺរ៉ុប យកចិត្តទុកដាក់បន្ថែមទៀតទៅលើកំណើនបៃតងរយៈពេលវែងពីការគ្រប់គ្រងប្រកបដោយចីរភាពនៃបរិស្ថាននិងធនធានធម្មជាតិរបស់កម្ពុជា ដោយធ្វើការអនុវត្តនូវវិធានការជាច្រើន។ វិធានការទាំងនេះអាចរួមមានៈ ការបង្កើនជំនួយអភិវឌ្ឍន៍ដល់រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ការកែលម្អការប្រមូលព័ត៌មាន និងការបង្ហាញព័ត៌មាន ការគាំទ្រដល់សម្លេងនិងអភិបាលកិច្ច ជាពិសេសសម្រាប់យុវជនកម្ពុជា ការលើកកម្ពស់សហប្រតិបត្តិការថ្នាក់តំបន់ និង ការលើកកម្ពស់ការទទួលខុសត្រូវសង្គមនិងបរិស្ថាននៅក្នុងវិស័យឯកជន។

ឯកឧត្តមឯកអគ្គរដ្ឋទូត ហ្សង់ហ្វង់ស័រ កូតាំង (Jean-François Cautain) ប្រធានសហភាពអឺរ៉ុបប្រចាំកម្ពុជា

No 100A – Preah Norodom Boulevard – Khan Daun Penh –12207 Phnom Penh – Cambodia
Tel: 855-23-216 996 / 211 102 / 220 611 / 220 612 – Fax: 855-23-216 997 – E-mail: Delegation-Cambodia@eeas.europa.eu
Website: http://ec.europa.eu/delegations/cambodia

បាន មានប្រសាសន៍ថា *"គោលដៅរយៈពេលវែងមួយក្នុងចំណោមគោលដៅផ្សេងៗនៃកិច្ចសហប្រតិបត្តិការរបស់សហភាពអឺរ៉ុបនៅក្នុងប្រទេសកម្ពុជា គឺការអភិវឌ្ឍប្រកបដោយចីរភាព ពោលគឺ ការរក្សាតុល្យភាពឱ្យបានល្អបំផុតនូវកំណើនសេដ្ឋកិច្ចនិងការការពារបរិស្ថាន ។ សហភាពអឺរ៉ុបជឿថា ព័ត៌មានស្ដីអំពីស្ថានភាពបរិស្ថានរបស់ប្រទេស នឹងជាប្រភពដ៏សំខាន់មួយនៃព័ត៌មានមូលដ្ឋាន និងរួមចំណែកដល់កិច្ចពិភាក្សានយោបាយ និងសហប្រតិបត្តិការ ដើម្បីលើកកម្ពស់ការយល់ដឹងឱ្យកាន់តែប្រសើរអំពីបញ្ហាប្រឈមដែលបង្កឡើងដោយការអភិវឌ្ឍប្រកបដោយចីរភាព"*។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោកស្រី ពូន ប៉ុក នៅប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា តាមទូរស័ព្ទលេខ ០២៣ ២១៦ ៩៩៦ ឬអ៊ីមែល: pok.poun@eeas.europa.eu